ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដំណាំពោតក្រហម





# ដំណាំពោតក្រហម

## ១-ផ្ទៃដីដាំដុះ និងបរិមាណផល ឆ្នាំ២០១៩-២០២០

| ឆ្នាំ | ផ្ទៃដីដាំដុះ (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (តោន/ហ.ត) | បរិមាណផលសរុប (តោន) |
|---|---|---|---|---|
| ២០១៩ | ២០០ ០៣៦ | ១៨៥ ៤៥៧ | ៤.៨៣ | ៨៩៥ ៤៣៦ |
| ២០២០ | ១៥៤ ៥៩៨ | ១៤៦ ៩៨៣ | ៥.០២ | ៧៣៧ ៦៩៣ |

## ២-ការនាំចេញពោតក្រហមកម្ពុជា ឆ្នាំ ២០១៩ - ឆ្នាំ ២០២០ និងរយៈពេល១០ខែ ឆ្នាំ២០២១

| បរិយាយ | បរិមាណ (តោន) | | | ទិសដៅនាំចេញ |
|---|---|---|---|---|
| | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ១០ខែ ឆ្នាំ២០២១ | |
| គ្រាប់ពោត | ១១៩ ៩៩៣,១៧ | ១៩៤ ៦២៥,២៨ | ១៥៧ ១៣៤,៣៦ | ថៃ វៀតណាម តៃវ៉ាន់ កូរ៉េ បង់ក្លាដេស |

ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រៅពីការនាំចេញផ្លូវការខាងលើ ផលិតផលពោតកម្ពុជាត្រូវបាននាំចេញក្រៅផ្លូវការតាមច្រករបៀងទៅប្រទេសជិតខាង។

## ៣-ផ្ទៃដីដាំដុះ និងបរិមាណផលពោតក្រហមតាមបណ្តាខេត្ត ឆ្នាំ២០២០

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីប្រមូលផល (ហ.ត) | បរិមាណផល (តោន) |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | 13,121 | 64,281 |
| ២ | បាត់ដំបង | 72,826 | 357,627 |
| ៣ | កំពង់ចាម | 6,744 | 42,657 |
| ៤ | កំពង់ឆ្នាំង | 0 | 0 |
| ៥ | កំពង់ស្ពឺ | 0 | 0 |
| ៦ | កំពង់ធំ | 0 | 0 |
| ៧ | កំពត | 290 | 870 |
| ៨ | កណ្តាល | 15,793 | 79,276 |
| ៩ | កោះកុង | 0 | 0 |
| ១០ | ក្រចេះ | 8,356 | 30,017 |
| ១១ | មណ្ឌលគីរី | 0 | 0 |
| ១២ | ភ្នំពេញ | 0 | 0 |

| | | | |
|---|---|---|---|
| ១៣ | ព្រះវិហារ | 1,402 | 6,997 |
| ១៤ | ព្រៃវែង | 7,058 | 49,406 |
| ១៥ | ពោធិសាត់ | 3,975 | 14,509 |
| ១៦ | រតនគីរី | 0 | 0 |
| ១៧ | សៀមរាប | 510 | 2,142 |
| ១៨ | ព្រះសីហនុ | 0 | 0 |
| ១៩ | ស្ទឹងត្រែង | 0 | 0 |
| ២០ | ស្វាយរៀង | 0 | 0 |
| ២១ | តាកែវ | 0 | 0 |
| ២២ | ឧត្តរមានជ័យ | 0 | 0 |
| ២៣ | កែប | 143 | 502 |
| ២៤ | ប៉ៃលិន | 5,805 | 34,830 |
| ២៥ | ត្បូងឃ្មុំ | 10,960 | 54,579 |
| **សរុប** | | **146,983** | **737,693** |

**៤-ទិន្នផល ÷** តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទិន្នផលជាមធ្យមគឺ៥.០២ តោន/ហ.ត (គ្រាប់ពោតស្ងួត)។ កសិករនៅស្រុកម៉ាឡៃដាំបានទិន្នផលពី៨ ទៅ ៩តោន/ហ.ត និងកសិករនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំដាំបានទិន្នផលពី៩ ទៅ១០តោន/ហ.ត (ពោតស្ងួលស្រស់) ។

**៥-ការស្រកស្រុត ÷**

- ពីពោតស្ងួលស្រស់ប្រឡេះចេញជាគ្រាប់ពោតស្រស់ក្នុងសំណើម ៣២%ទៅ៣៣% គឺស្រកអស់ ២២%ទៅ២៣%។
- សម្ងួតគ្រាប់ពោតពីសំណើម ៣២%ទៅ៣៣%មកនៅសំណើម ១៤.៥% ស្រកអស់ ២២%ទៅ២៣%។

ដូច្នេះនៅសល់បរិមាណគ្រាប់ពោតស្ងួត ៥៦%។

**៦-រយៈពេលដាំដុះ-ប្រមូលផល ÷** ៣ខែ ១៥ថ្ងៃ ទៅ ៣ខែ ២០ថ្ងៃ។ ក្នុង១ឆ្នាំដាំបាន២ដង

**៧-រដូវកាលដាំដុះ ÷**

**រដូវវស្សា ÷**ដាំពីចុងខែមេសាដល់ពាក់កណ្តាលខែឧសភានិងប្រមូលផលនៅចុងខែសីហានិងកញ្ញា

**រដូវប្រាំង ÷** ដាំពីចុងខែវិច្ឆិកាដល់មករា និងប្រមូលផលនៅចុងខែមីនានិងដើមខែមេសា

**៨-ទីផ្សារ ÷**

-តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងឆ្នាំ២០២០ គ្រាប់ពោតកម្ពុជាត្រូវបាននាំចេញទៅប្រទេសវៀតណាម ថៃ កោះតៃវ៉ាន់ ប្រទេសបង់ក្លាដេស និងប្រទេសកូរ៉េ

-កសិករលក់ពោតស្ងួលស្រស់ឱ្យអ្នកប្រមូលទិញ។ អ្នកប្រមូលទិញមាន២ក្រុមគឺ÷ ក្រុមអ្នកប្រមូលទិញជាប្រភេទឈ្មួញកណ្តាល និងក្រុមអ្នកប្រមូលទិញនិងនាំចេញហៅថាសៃឡូ។ ឈ្មួញកណ្តាលអាចមានឃ្លាំង និងឡសម្ងួតដែរប៉ុន្តែមិននាំចេញទេគឺសម្រាប់លក់បន្តឱ្យក្រុមហ៊ុននាំចេញ ឬសម្រាប់ផ្គត់ផ្គង់ឱ្យរោងចក្រផលិតចំណីសត្វក្នុងស្រុកមានដូចជា ក្រុមហ៊ុនស៊ីភី ក្រុមហ៊ុនបេតាក្រូ និងក្រុមហ៊ុនធំស្រួយលីលី។ សៃឡូនាំចេញនៅខេត្តបន្ទាយមានជ័យ និងប៉ៃលិនភាគច្រើនជាជនជាតិថៃ ប៉ុន្តែមានមេការជាជនជាតិខ្មែរជាអ្នកប្រមូលទិញពីកសិករ។

-ជាទូទៅតម្លៃពោតមានការប្រែប្រួលទៅតាមទីផ្សារក្រៅប្រទេស ប៉ុន្តែតម្លៃដែលកសិករទទួលបានគឺប្រែប្រួលតាមគុណភាពសំណើមពោត។ ការវាយតម្លៃពីគុណភាពគ្រាប់ពោតគឺសំដៅតែទៅលើបរិមាណសំណើមដែលមាននៅជាមួយគ្រាប់ពោត ហើយការវាយតម្លៃបរិមាណសំណើមគឺយោងតាមចំនួនថ្ងៃទុកឱ្យទុំ។ ពោតដែលមានសំណើមអាចទិញបានគឺទុកឱ្យវាទុំល្អ (រយៈពេល ៣ខែ១០ថ្ងៃ ទៅ ៣ខែ ២០ថ្ងៃ)។

**៩-ខ្សែច្រវ៉ាក់តម្លៃ** (តម្លៃនៅចុងឆ្នាំ២០២០)

**កសិករ**
ពុំមានកិច្ចសន្យាផលិតកម្ម
លក់ពោតស្ងួលតម្លៃ៥បាត/គ.ក
ថ្លៃដើម/គ.ក= ៣បាត= ៣៩៩៛
ចំណេញ/គ.ក=១.៩បាត= ២៥២៛

→

**សៃឡូ**
-លក់គ្រាប់ពោតស្ងួតក្នុងតម្លៃ ៩.៦-៩.៨បាត/គ.ក
-ក្នុង១តោនគ្រាប់ពោតស្ងួតចំណាយអស់៣០០បាត សម្រាប់ការប្រឡេះគ្រាប់ សម្ងួត ថ្លៃលើកដាក់
ថ្លៃដើម/គ.ក= ៩.២៨បាត=១២៣៤៛
ចំណេញ/គ.ក= ០.៣២បាត= ៤៣៛

↓

**ឈ្មួញកណ្តាល**
ជាអ្នកនាំចេញលក់ឱ្យរោងចក្រកែច្នៃនៅថៃ និងក្រុមហ៊ុននាំចេញបន្ត
-លក់ក្នុងតម្លៃ ១១.៣០បាត/គ.ក
-ចំណាយលើថ្លៃដឹកជញ្ជូន ៤០០បាត/តោន
-ចំណាយលើការបង់ច្រក CO, Shipping សរុប ០.២៥បាត/គ.ក
-កម្មករលើកដាក់ ០.៣០បាត/គ.ក
-សរុបចំណាយ = ១០.៥៥បាត/គ.ក
-ចំណេញ= ១១.៣០ - ១០.៥៥ = ០.៧៥បាត/គ.ក=១០០៛/គ.ក

ប្រភព÷
-លោក ចាន់ វិន ប្រធានសហគមន៍កសិកម្មឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ ០៩៧ ៣៧ ៤៧ ៣០៥
-លោក ថៃ យិន សៃឡូទិញកសិផលនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ ០១២ ៦៨៨ ៨១០

## ១០-លក្ខណៈរបស់អ្នកពាក់ព័ន្ធក្នុងខ្សែច្រវ៉ាក់ដំណាំពោតក្រហម

| អ្នកផ្គត់ផ្គង់ធាតុចូល | អ្នកផលិត | អ្នកប្រមូលទិញនិងនាំចេញ |
|---|---|---|
| •លក់គ្រាប់ពូជ<br>•លក់ធាតុចូល ជី ថ្នាំសម្លាប់ស្មៅ ថ្នាំបំប៉ន<br>•ផ្តល់ព័ត៌មានពីធាតុចូលទៅតាមការយល់ឃើញ ឬតៗគ្នា គ្មានជំនាញ ដូចនេះគេមិនអាចការផ្តល់ព័ត៌មានឱ្យបានជាក់លាក់ដល់កសិករដែលជួបបញ្ហា<br>•ជួលគ្រឿងចក្រ និងលក់សេវាពលកម្មជួយថែទាំ និងប្រមូលផល។ | •អនុវត្តការដាំដុះតាមគ្នា និងទីផ្សារ<br>•ខ្វះខាតបច្ចេកទេសដាំដុះ<br>•នៅពេលពោតកើតជំងឺទៅរកថ្នាំពីអ្នកផ្គត់ផ្គង់ធាតុចូលតាមផ្សារយកមកព្យាបាល<br>•ត្រូវតែលក់កសិផលទោះជាខាតក្តីព្រោះមិនអាចស្តុកទុកបាន<br>•តម្លៃប្រែប្រួលតាមទីផ្សារក្រៅប្រទេស និងតាមគុណភាពពោតដែលជាគន្លឹះឱ្យតម្លៃថោកពីឈ្មួញ | •ឈ្មួញកណ្តាល<br>•រោងចក្រផលិតចំណីសត្វ<br>•សៃឡូនាំចេញ<br>•សៃឡូពឹងផ្អែកតែលើទីផ្សារថៃ និងវៀតណាម<br>•ឈ្មួញជាអ្នកខាតបើស្រែកទម្ងន់ និងគុណភាពមិនល្អ<br>•តម្រូវការក្នុងស្រុកមានបរិមាណតិចតួច |

## ១១-ថ្លៃដើមផលិតកម្មនិងការវិភាគសេដ្ឋកិច្ច

### ១១.១-កសិករនៅស្រុកម៉ាឡៃ ( ប្រាំង និងវស្សា )÷

| ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (បាត) | សរុប (ជាបាត) ផ្ទៃដី ១រ៉ៃ | សរុប (ជាបាត) ផ្ទៃដី១ហិកតា (១ហ.ត=៦.២៥រ៉ៃ) | សរុប (ជារៀល) ផ្ទៃដី១ហិកតា ១បាត=១៣៣៛ |
|---|---|---|---|---|---|---|
| ថ្លៃភ្ជួររាស់ ( ផាលពាឬផាល៤) | លើក | 1 | 300.00 | 300.00 | 1,875.00 | 249,375.00 |
| ថ្លៃសាប់ដី ( ផាល៧) | លើក | 1 | 200.00 | 200.00 | 1,250.00 | 166,250.00 |
| ឈ្នួលដាំ | លើក | 1 | 130.00 | 130.00 | 812.50 | 108,062.50 |
| ជី ១៥ x ១៥ | គ.ក | 17 | 15.60 | 265.20 | 1,657.50 | 220,447.50 |
| ពូជ | គ.ក | 3 | 185.00 | 555.00 | 3,468.75 | 461,343.75 |
| ថ្នាំបាញ់ស្មៅ ( ពោតអាយុ២០ថ្ងៃ) | លើក | 1 | 35.00 | 35.00 | 218.75 | 29,093.75 |
| ថ្លៃបាញ់ស្មៅ | នាក់ | 2 | 300.00 | 600.00 | 3,750.00 | 498,750.00 |
| ថ្នាំប៉ូវលើកទី១ ( ពោតអាយុ១ខែទៅ១ខែកន្លះ) | លើក | 1 | 40.00 | 40.00 | 250.00 | 33,250.00 |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី១(១ថ្ងៃ) | នាក់ | 2 | 300.00 | 600.00 | 3,750.00 | 498,750.00 |
| ថ្នាំប៉ូវលើកទី២ ( ពោតអាយុ២ខែទៅ២ខែកន្លះ) | លើក | 1 | 40.00 | 40.00 | 250.00 | 33,250.00 |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី២(១ថ្ងៃ) | នាក់ | 2 | 300.00 | 600.00 | 3,750.00 | 498,750.00 |
| កម្មករកាច់ ៨៥គ.ក/១ការុង= ៥០០០៛ ទិន្នផល ១រ៉ៃ=១៨ការុង ( ពោតស្ងួល) | ការុង | 18 | 41.00 | 738.00 | 4,612.50 | 613,462.50 |
| ថ្លៃកម្មករលើកដាក់អាត្រាក់ | ការុង | 18 | 10.00 | 180.00 | 1,125.00 | 149,625.00 |
| ថ្លៃដឹក គិតការុង ២៥បាត/ ការុង ទិន្នផល ១រ៉ៃ=១៨ការុង x៨៥គ.ក=១៥៣០គ.ក | ការុង | 18 | 25.00 | 450.00 | 2,812.50 | 374,062.50 |
| **ចំណាយសរុប** | | | | **4,733.20** | **29,582.50** | **3,934,472.50** |
| **ចំណូលសរុប** | | | | | | |
| លក់ពោតស្ងួល ( ទិន្នផល ១៥៣០គ.ក/រ៉ៃ) តម្លៃដើមឆ្នាំ២០២០ ពី ៤.៨បាត-៥.២បាត/ គ.ក គិតតម្លៃជាមធ្យម ៥បាត/ គ.ក | គ.ក | 1,530 | 5.00 | **7,650.00** | **47,812.50** | **6,359,062.50** |
| **ចំណេញសរុប** | | | | **2,916.80** | **18,230.00** | **2,424,590.00** |

## ១១.២-កសិករនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ÷

### ក/-សម្រាប់ការដាំដុះនៅរដូវវស្សា លើផ្ទៃដី១ហិកតា÷

| ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) |
|---|---|---|---|---|
| ថ្លៃភ្ជួររាស់ | លើក | 1.00 | 250,000.00 | 250,000.00 |
| ថ្លៃភ្ជួរប្រែដី សាប់ និងឆ្វៀលគន្លងដាំ | លើក | 1.00 | 280,000.00 | 280,000.00 |
| ឈ្នួលដាំ (អ្នកដើរដាក់គ្រាប់តាមគន្លង) | នាក់ | 4.00 | 25,000.00 | 100,000.00 |
| ជីទ្រាប់បាត ១៥ x ១៥ | បេ | 2.00 | 120,000.00 | 240,000.00 |
| ពូជ | គ.ក | 20.00 | 23,000.00 | 460,000.00 |
| ថ្នាំបាញ់ស្មៅ មុនពេលភ្ជួរ (សញ្ញារូបសេះ) | លើក | 1.00 | 79,000.00 | 79,000.00 |
| ថ្នាំកក់ មុនពេលភ្ជួរ | លើក | 1.00 | 16,000.00 | 16,000.00 |
| ថ្លៃបាញ់ថ្នាំស្មៅ និងថ្នាំកក់មុនពេលភ្ជួរ | លើក | 1.00 | 100,000.00 | 100,000.00 |
| ថ្នាំស្មៅ ពេលពោតអាយុបាន២០-៣០ថ្ងៃ | លើក | 1.00 | 48,000.00 | 48,000.00 |
| ថ្លៃបាញ់ថ្នាំស្មៅ | លើក | 1.00 | 40,000.00 | 40,000.00 |
| ថ្នាំដង្កូវ (UT, អង់ទ្រីន ) | ដង | 4.00 | 12,500.00 | 50,000.00 |
| ថ្លៃបាញ់ថ្នាំដង្កូវ | លើក | 1.00 | 40,000.00 | 40,000.00 |
| ឈ្នួលកាច់ | នាក់ | 8.00 | 25,000.00 | 200,000.00 |
| ឈ្នួលបកសំបក (១ជាល=២០គ.ក ពោតស្ងួលតម្លៃ ៦០០៛/ជាល) ទិន្នផលពី៨ ទៅ១០តោន/ហ.ត គិតជាមធ្យម ៩តោន=៤៥០ជាល | ជាល | 450.00 | 600.00 | 270,000.00 |
| **ចំណាយសរុប** | | | | **2,173,000.00** |
| **ចំណូលសរុប** | | | | |
| លក់ពោតស្ងួលស្រស់ ឈ្មួញចុះមកទិញដល់ផ្ទះ (តម្លៃ៦០០៛/គ.ក) ទិន្នផលពី៨ ទៅ១០តោន/ហ.ត គិតជាមធ្យម ៩តោន/ហ.ត | គ.ក | 9,000.00 | 600.00 | **5,400,000.00** |
| **ចំណេញសរុប** | | | | **3,227,000.00** |

## ១/-សម្រាប់ការដាំដុះនៅរដូវប្រាំង លើផ្ទៃដី១ហិកតា ÷

| ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) |
|---|---|---|---|---|
| ថ្លៃភ្ជួររាស់ | លើក | 1.00 | 250,000.00 | 250,000.00 |
| ថ្លៃភ្ជួរប្រែដី សាប់ និងឆ្វតគន្លងដាំ | លើក | 1.00 | 280,000.00 | 280,000.00 |
| ឈ្នួលដាំ (អ្នកដើរដាក់គ្រាប់តាមគន្លង) | នាក់ | 4.00 | 25,000.00 | 100,000.00 |
| ជីទ្រាប់បាត ១៥ x ១៥ | បេ | 2.00 | 120,000.00 | 240,000.00 |
| ពូជ | គ.ក | 20.00 | 23,000.00 | 460,000.00 |
| ថ្នាំបាញ់ស្មៅ មុនពេលភ្ជួរ (សញ្ញារូបសេះ) | លើក | 1.00 | 79,000.00 | 79,000.00 |
| ថ្នាំកក់ បាញ់មុនពេលភ្ជួរ | លើក | 1.00 | 16,000.00 | 16,000.00 |
| ថ្លៃបាញ់ថ្នាំស្មៅ និងថ្នាំកក់ មុនពេលភ្ជួរ | លើក | 1.00 | 100,000.00 | 100,000.00 |
| ថ្នាំស្មៅ ពេលពោតអាយុបាន២០-៣០ថ្ងៃ | លើក | 1.00 | 48,000.00 | 48,000.00 |
| ថ្លៃបាញ់ថ្នាំស្មៅ | លើក | 1.00 | 40,000.00 | 40,000.00 |
| ថ្នាំដង្កូវ (UT, អង់ទ្រីន ) | ដង | 4.00 | 12,500.00 | 50,000.00 |
| ថ្លៃបាញ់ថ្នាំដង្កូវ | លើក | 1.00 | 40,000.00 | 40,000.00 |
| ជួលគេបូមទឹកស្រោចស្រព (ប្រេងលើម្ចាស់ចម្ការ) | ម៉ោង | 24.00 | 5,000.00 | 120,000.00 |
| ប្រេងបូមទឹក (១០ម៉ោង= ៨លីត្រ) | លីត្រ | 20.00 | 2,800.00 | 56,000.00 |
| ឈ្នួលកាច់ | នាក់ | 8.00 | 25,000.00 | 200,000.00 |
| ឈ្នួលបកសំបក (១ជាល= ២០គ.ក ពោតស្ងួលតម្លៃ ៦០០៛/ ជាល) ទិន្នផលពី៨ ទៅ៩តោន/ ហ.ត គិតជាមធ្យម ៨.៥តោន= ៤២៥ជាល | ជាល | 425.00 | 600.00 | 255,000.00 |
| **ចំណាយសរុប** | | | | **2,334,000.00** |
| **ចំណូលសរុប** | | | | |
| លក់ពោតស្ងួលស្រស់ ឈ្មួញចុះមកទិញដល់ផ្ទះ (តម្លៃ៦០០៛/ គ.ក) ទិន្នផលពី៨ ទៅ៩តោន/ ហ.ត គិតជាមធ្យម ៨.៥តោន/ ហ.ត | គ.ក | 8,500.00 | 600.00 | **5,100,000.00** |
| **ចំណេញសរុប** | | | | **2,766,000.00** |

ប្រភព÷ លោកស្រី សុខ ម៉េង សមាជិកបណ្ដុំកសិករនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

ទូរស័ព្ទ÷ ០៨៨ ៤០០ ៣៤៥៨

**៩-បច្ចេកទេសដាំដុះ**

**ក.ការជ្រើសរើស និងការរៀបចំដី÷**

-ធ្វើការជ្រើសរើសដីដែលប្រោះទឹកល្អ មិនហាប់ណែន មានជីជាតិ និងមាន pH ប្រមាណពី៦-៧។ ដីដែលសមស្របសម្រាប់ដំណាំពោតគឺជាដីខ្ពស់មិនលិចទឹក ឬដីតាមជម្រាលភ្នំ និងដីក្រហម។ ដើម្បីឱ្យដំណាំពោតដុះលូតលាស់ល្អនិងបានទិន្នផលខ្ពស់ត្រូវជ្រើសរើសដីផុសមិនហាប់ ដីដែលមានជីជាតិច្រើន ហើយគ្មានជាតិជូរឬប្រៃខ្លាំង។

-ត្រូវធ្វើការភ្ជួរដីដែលមានសំណើម៣០-៦០ភាគរយ។ ការភ្ជួរដីសើមពេកឬស្ងួតពេកជាហេតុបណ្តាលឱ្យប៉ះពាល់ដល់គុណភាពដី។ ការរៀបចំដីដាំពោតត្រូវធ្វើឱ្យមានសភាពម៉ត់ល្អ ដែលអាចឱ្យយើងបង្កប់គ្រាប់ចូលទៅក្នុងដីបាន និងគ្រាប់ស្ថិតនៅក្នុងលទ្ធភាពដែលអាចទទួលសំណើមបានគ្រប់គ្រាន់។

-ភ្ជួរលើកទី១ ឱ្យបានជំរៅពី ១៥ ទី ២៥សង្ទីម៉ែត្រ (១,៥ ទៅ ២,៥តឹក) បន្ទាប់ពីភ្ជួរហើយត្រូវរាស់បំបែកដីឱ្យម៉ដ្ឋល្អ

-ភ្ជួលើកទី២ រយៈមួយអាទិត្យក្រោយភ្ជួរលើកទី១ រួចបាចជីលាមកសត្វ ឬកំប៉ុស្តទ្រាប់បាតរាស់បំបែកដីឱ្យម៉ដ្ឋ និងលុបជីចូលទៅក្នុងដី រួចលើករងដាំឬបុកដាំ។

**ខ.ការជ្រើសរើសពូជ÷**

ត្រូវជ្រើសរើសពូជដែលសុទ្ធ មានគុណភាពល្អមិនមានជំងឺ និងសត្វល្អិតបំផ្លាញ ដែលមានដំណុះគ្រាប់ខ្ពស់ពី៨៥-៩០%។ ត្រូវយកគ្រាប់ស្ងួតដែលមានសំណើម១៣% ទៅត្រាំទឹករយៈពេល៤-៦ម៉ោង ដើម្បីបង្កើនអត្រាដុះនៃគ្រាប់ បន្ទាប់មកយកគ្រាប់នោះទៅលាយជាមួយថ្នាំ Captance 50WP ដោយប្រើក្នុងកម្រិត ៣០០ក្រាម លាយជាមួយគ្រាប់ពោត ១០០គ.ក ដើម្បីការពារផ្សិត។

**គ.វិធីសាស្ត្រដាំដុះ÷**

**-ចំនួនដើម/គុម្ព និងគម្លាតគុម្ពៈ** ការដាំដុះដំណាំពោតត្រូវកំណត់នូវចន្លោះគុម្ពឱ្យបានត្រឹមត្រូវដែលជាកត្តាសំខាន់ពាក់ព័ន្ធដល់ទិន្នផល បើអនុវត្តមិនបានត្រឹមត្រូវនាំឱ្យផលដែលទទួលបានមានបរិមាណតិច ដោយសារការបាត់បង់ចំនួនដើម និងមានផ្លែតូចៗប្រសិនបើដាំញឹកពេក។

| ពូជ | ចន្លោះគុម្ព (ស.ម) | ចំនួនដើ/គុម្ព | ចំនួនដើម/ហិកតា |
|---|---|---|---|
| ពូជស្រាល (៨៥-១០៥ ថ្ងៃ) | ៧០ x ២៥ | ១ | ៥៥ ០០០ |
| | ៧០ x ៥០ | ២ | ៥៧ ០០០ |
| ពូជកណ្តាល (១០៥-១៣០ ថ្ងៃ) | ៧០ x ៣០ | ១ | ៤៧ ០០០ |
| | ៧០ x ៦០ | ២ | ៥ ០០០ |
| ពូជធ្ងន់ (វែងជាង ១៣០ថ្ងៃ) | ៧០ x ៣៥ | ១ | ៤០ ០០០-៤២ ០០០ |

**-ជម្រៅនៃការដាំ:** គេអាចដាំពោតតាមពីររបៀបបុកដាំ និងលើករងដាំ។ ជម្រៅនៃការដាំគឺអាស្រ័យទៅនឹងប្រភេទដី សំណើមដីនិងរដូវកាលដាំដុះ។ ចំពោះរដូវវស្សាដីសើម ការកប់គ្រាប់មានជម្រៅរាក់ល្មមប្រមាណ ៣-៥ស.ម ចំណែកនៅរដូវប្រាំងគឺមានជម្រៅ ៥-៨ស.ម។ ទុកចន្លោះជួរ ៥តឹក និងចន្លោះគុម្ព ២តឹក ទៅ ៣តឹក។

**-ការប្រើប្រាស់ជី:** ការប្រើប្រាស់ជីគឺទៅតាមប្រភេទដី។ នៅតំបន់ដីខ្សាច់ប្រើជីអ៊ុយរ៉េ ជី DAP សម្រាប់ទ្រាប់បាត និងសម្រាប់បំប៉នពេលពោតមានអាយុ៣-៤សប្តាហ៍។

**ឃ.ការថែទាំ**

**-វិធីដករំលោះកូន:** ដករំលោះកូនក្រោយដាំបាន១៥ថ្ងៃដោយទុកតែ១-២ដើមក្នុង១គុម្ព ដោយទុកដើមណាដែលមានសភាពថ្លោសរឹងមាំក្នុងការលូតលាស់។

**-ការធ្វើស្មៅ និងដាក់ជី:** ក្រោយពេលដករំលោះកូន ចាប់ផ្តើមធ្វើស្មៅ លុះរយៈពេល៣០ថ្ងៃក្រោយពេលពោតមានស្លឹកពី៦-៨សន្លឹកត្រូវធ្វើស្មៅដាក់ជីជាលើកទី២។ ជីបំប៉នត្រូវដាក់ក្រោយពីដាំបានរយៈពេល ១០ថ្ងៃ ដាក់នៅឆ្ងាយពីគល់ ១តឹក រួចពូនដីលុបឱ្យជិតកុំឱ្យទឹកហូរច្រោះ និងទប់ដើម។

**ង.ការប្រមូលផល**

នៅពេលលក្ខណៈរូបរបស់ដើមមានពណ៌លឿងស្គូត ស្លឹកពណ៌លឿងទុំ សំបកផ្លែក្រៀមស្រួយដូចក្រដាស សក់ពោតឡើងខ្មៅស្រួយ គ្រាប់ភ្លឺរលោងហើយរឹង សំណើមក្នុងគ្រាប់ទាបជាង២៥% គឺជាពេលវេលាសមស្របសម្រាប់ការប្រមូលផល។ ពោតដែលប្រមូលផលផលហើយគួរសម្ងួតរហូតដល់សំណើមគ្រាប់ស្ថិតនៅត្រឹម១២-១៤%។

**ច.ការទុកដាក់ពូជ**

ដើម្បីទុកពូជដាំបានល្អ ត្រូវជ្រើសរើសដើមដែលល្អ មិនខ្ពស់ពេក ឬទាបពេក ពុំមានជំងឺនិងសត្វល្អិតបំផ្លាញ ពូជផ្តល់ទិន្នផលខ្ពស់។ គ្រាប់ពូជត្រូវហាលឱ្យស្ងួតដល់សំណើមក្នុងគ្រាប់នៅសល់ ១៣ ដល់ ១៤ភាគរយរក្សាទុកកន្លែងដែលមានខ្យល់ចេញចូល។

## ១០-ចំណុចខ្លាំង

-ដំណាំពោតក្រហមអាចដាំបាន២ដងក្នុង១ឆ្នាំ

-កសិករតែងផ្តល់បទពិសោធន៍ពីភាពជោគជ័យនៃការដាំឱ្យគ្នាទៅវិញទៅមក ដែលធ្វើឱ្យកសិករមានការយល់ដឹងកាន់តែច្បាស់ពីវិធីនៃការដាំដុះពី១ឆ្នាំទៅ១ឆ្នាំ ដែលអាចទទួលបានចំណូលសមរម្យ

-គ្រួសារនៅជនបទអាចរកប្រាក់ចំណូលនិងកម្រៃពីការស៊ីឈ្នួលពលកម្មលើការដាំដុះការប្រមូលផលផ្លែពោត និងបកសំបកពោត។

-រកចំណូលបានសមរម្យ មិនសូវហត់នឿយ ស្ត្រីក៏អាចគ្រប់គ្រងការដាំដុះបានដែរ។

## ១១-បញ្ហាប្រឈម

-ដំណាំពោតក្រហមងាយនឹងងាប់ប្រសិនបើជួបនឹងភាពរាំងស្ងួតត្រឹម១ខែ  មិនដូចដំណាំដំឡូងមីដែលកម្រងាប់ណាស់ព្រោះធន់នឹងភាពរាំងស្ងួត។

-កសិករដាំដុះតាមរបៀបផ្សងព្រេង  ឆ្នាំខ្លះបានផល  ឆ្នាំខ្លះក៏មិនបានផលអាស្រ័យលើធម្មជាតិដោយពេលខ្លះជួបនឹងបញ្ហាគ្រោះធម្មជាតិរាំងស្ងួត ពុំសូវមានទឹកភ្លៀងគ្រប់គ្រាន់ សត្វល្អិតដង្កូវស៊ីបំផ្លាញ

-ខបច្ចេកទេសដាំដុះ កសិករភាគច្រើនគឺដាំតាមទម្លាប់ប្រពៃណីទាំងស្រុងប្រាប់តៗគ្នា